រាជធានីភ្នំពេញ ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ១៩៩៦

# ប្រកាសលេខ ១៥៨ អយក.ប្រក

## ស្តីពីការប្តូរឈ្មោះ វិទ្យាល័យបានលុង ទៅជាវិទ្យាល័យ សម្តេចឳ—សម្តេចម៉ែ ស្ថិតនៅក្នុងស្រុក បានលុង ខេត្តរតនគិរី

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ។
- យោងលិខិតរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តរតគីរី លេខ ៥៦១/៩៥ អយក.សណ ចុះថ្ងៃទី ២៧–១១–៩៥ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យបានលុង បច្ចុប្បន្នជា «វិទ្យាល័យ **សម្តេចឳ - សម្តេចម៉ែ**» ចាប់ពីបវេសនកាល ឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគីរី និង

នាយកវិទ្យាល័យ សម្តេចឪ សម្តេចម៉ែ មានភារកិច្ចរៀង ។ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ១៦៣ អយក.ប្រក**

**ស្តីពីប្តូរឈ្មោះសាលាបឋមសិក្សាពោធិមន្ទ**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤ ។
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណោះទូទៅ ។
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្តីពីការកំណត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំយុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង លេខ ៩០-៩៥ ចុះថ្ងៃទី ១៤-១០-៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណោះទូទៅ និងមត្តេយ្យសិក្សា